# អនុសញ្ញា

# រវាង

# ព្រះរាជាណាចក្រកម្ពុជា

# សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

# និងសាធារណរដ្ឋសង្គមនិយមវៀតណាម

# ស្ដីពីការកំណត់ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី

ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវហៅថា "ភាគីគូសន្យាទាំងបី"

ក្នុងគោលបំណងថែរក្សាផលប្រយោជន៍ជាមូលដ្ឋាននៃប្រជាជនរបស់ខ្លួន ពង្រឹងបន្ថែមនូវទំនាក់ទំនងល្អជាប្រទេសជិតខាងផងគ្នាដែលធ្លាប់មានពីមុនមក មិត្តភាពរវាងប្រទេសទាំងបី និងរៀបចំបង្កើតតំបន់ព្រំដែនត្រីកោណមួយ ជាតំបន់សន្តិភាព មិត្តភាព និងសហប្រតិបត្តិការយូរអង្វែង

ឈរលើគោលការណ៍សមភាព គោរពគ្នាទៅវិញទៅមកនូវអធិបតេយ្យភាព បូរណភាពទឹកដី និងផលប្រយោជន៍ស្របច្បាប់រៀង១ខ្លួន

បានសម្រេចលើខ្លឹមសារនៃអនុសញ្ញាមានដូចតទៅ :

## មាត្រា ១

១. ភាគីគូសន្យាទាំងបីឯកភាពគ្នាថា ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម ស្ថិតនៅត្រង់ចំណុចជួបគ្នានៃខ្សែព្រំដែនរវាងកម្ពុជា-ឡាវ ចំណុចជួបគ្នានៃខ្សែព្រំដែនរវាងឡាវ-វៀតណាម និងចំណុចជួបគ្នានៃខ្សែព្រំដែនរវាងកម្ពុជា-វៀតណាម នៅលើកំពូលភ្នំ ត្រង់ចំណុចដែលមានរយៈកំពស់ ១០៨៦ វាស់នៅលើផែនទី។

ចំណុចប្រសព្វនេះមានចម្ងាយ ២.៣០គម ពីចំណុចដែលមានរយៈកំពស់ ៩៣០ នៅទិសនិរតីក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ ១.៨៣គម ពីចំណុចដែលមានរយៈកំពស់ ៩០៥ នៅទិសខាងជើង-ពាយ័ព្យក្នុងទឹកដីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងមានចម្ងាយ ៣.១១គម ពីចំណុចដែលមានរយៈកំពស់ ៩១៨ នៅទិសអាគ្នេយ៍ក្នុងទឹកដីនៃ សាធារណរដ្ឋសង្គមនិយមវៀតណាម (វាស់នៅលើ

ផែនទីខ្នាត១/៥០.០០០ ដែលជាឧបសម្ព័ន្ធនៃអនុសញ្ញាស្តីពីការកំណត់ចំណុចប្រសព្វនៃខ្សែព្រំដែនប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម ។

២. និយាមកាក្រឡាចត្រង្គនៃចំណុចប្រសព្វនៃខ្សែព្រំដែនរវាងប្រទេសទាំងបីគឺៈ N=X=1625161.02 m, E=Y=775331.60 m និងនិយាមកាភូមិសាស្ត្រនៃចំណុចប្រសព្វនៃខ្សែព្រំដែនរវាងប្រទេសទាំងបី គឺៈ B=14°41'09.80", L=107°33'23.79" ដែលមានរយៈកំពស់ ១០៨១ (វាស់វែងនៅលើដីជាក់ស្តែង) ។

៣. ចំណុចប្រសព្វនៃខ្សែព្រំដែនរវាងប្រទេសទាំងបី ត្រូវបានស្តែងឡើងដោយចំណុចពណ៌ក្រហម ដែលជាមណ្ឌលនៃរង្វង់មូលមានអង្កត់ផ្ចិត ៣ម.ម តំណាងឱ្យចំណុចទីតាំងបង្គោលព្រំដែននៅលើផែនទីខ្នាត ១/៥០.០០០ ដែលបានចុះហត្ថលេខាទទួលស្គាល់ដោយភាគីគូសន្យាទាំងបី ។ ផែនទីនេះត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធជាមួយអនុសញ្ញានេះ ហើយជាផ្នែកមួយដែលមិនអាចកាត់ផ្តាច់ពីអនុសញ្ញានេះបានឡើយ ។

## មាត្រា ២

១. ភាគីគូសន្យាទាំងបីឯកភាពបោះបង្គោលព្រំដែនមួយផលិតអំពីថ្មក្រានីត ត្រង់ចំណុចពិតប្រាកដនៃចំណុចប្រសព្វនៃខ្សែព្រំដែនរវាងប្រទេសទាំងបី (តាមប្លង់ ទីតាំងឋានលេខាបង្គោលព្រំដែន ចំណុចប្រសព្វ និងកំណត់ហេតុបោះបង្គោលព្រំដែនដែលភ្ជាប់ជាឧបសម្ព័ន្ធនៃអនុសញ្ញានេះ) ។

២. ភាគីគូសន្យាទាំងបីត្រូវថែទាំបង្គោលព្រំដែន និងត្រូវចាត់វិធានការចាំបាច់នានា ដើម្បីទប់ស្កាត់កុំឱ្យបង្គោលព្រំដែនត្រូវបានបង្ខិត ដែលបណ្តាលឱ្យមានការខូចខាត ឬត្រូវបំផ្លិចបំផ្លាញបង្គោលព្រំដែននោះ ។ ភាគីគូសន្យានីមួយៗមិនអាចបង្ខិត ផ្លាស់ប្តូរទម្រង់បង្គោលព្រំដែន និងសាងសង់បង្គោលព្រំដែនថ្មីណាមួយជាឯកតោភាគីបានឡើយ ។

៣. ក្នុងករណីដែលភាគីគូសន្យាណាមួយសង្កេតឃើញថា បង្គោលព្រំដែនត្រូវបានបង្ខិត ធ្វើឱ្យខូចខាត ឬបំផ្លិចបំផ្លាញ ភាគីគូសន្យានេះត្រូវផ្តល់ដំណឹងជូនទៅដល់ភាគីគូសន្យាពីរផ្សេងទៀតឱ្យបានឆាប់បំផុត ។ ភាគីគូសន្យាទាំងបីនឹងត្រូវយោងដោយយកទីតាំងពិតប្រាកដរបស់បង្គោលព្រំដែនដូចដែលមានចែងក្នុងមាត្រា ១ នៃអនុសញ្ញានេះ នូវគំរូ ទ្រង់ទ្រាយរបស់បង្គោលព្រំដែន ដូចដែលបានកំណត់ក្នុងប្លង់សាងសង់បង្គោលព្រំដែនដើមនៅចំណុចប្រសព្វនៃប្រទេសទាំងបី កម្ពុជា ឡាវ និងវៀតណាម ដែលជាឧបសម្ព័ន្ធនៃអនុសញ្ញានេះ ដើម្បីកសាង និងដាក់ឱ្យត្រូវចំទីតាំងចាស់ឡើងវិញ ហើយត្រូវចុះហត្ថលេខាលើកំណត់ហេតុរួមគ្នាមួយបន្ទាប់ពីធ្វើការជួសជុលរួចរាល់ហើយ ។

## មាត្រា ៣

អនុសញ្ញានេះ នឹងត្រូវផ្តល់សច្ចាប័ន ដោយភាគីនីមួយៗ ទៅតាមនីតិវិធីច្បាប់របស់ប្រទេសរៀងៗខ្លួន។ ភាគីទាំងបីត្រូវជូនដំណឹងគ្នាទៅវិញទៅមកតាមរយៈផ្លូវទូត អំពីការផ្តល់សច្ចាប័ននេះ។ អនុសញ្ញានេះនឹងចូលជាធរមានចាប់ពីថ្ងៃជូនដំណឹងចុងក្រោយ។

ធ្វើជាបីច្បាប់ នៅទីក្រុងហាណូយ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០០៨ ជាភាសាខ្មែរ ឡាវ និងវៀតណាម អត្ថបទទាំងបីភាសានេះ មានតម្លៃស្មើគ្នា។ ភាគីគូសន្យាទាំងបីឯកភាពអនុម័តយកអត្ថបទជាភាសាបារាំងសម្រាប់ធ្វើការប្រៀបធៀប។

| | | |
|---|---|---|
| **តំណាងពេញសិទ្ធិនៃ** | **តំណាងពេញសិទ្ធិនៃ** | **តំណាងពេញសិទ្ធិនៃ** |
| ព្រះរាជាណាចក្រកម្ពុជា | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | សាធារណរដ្ឋសង្គមនិយមវៀតណាម |
| **ហ៊ា គីមហុង** | **ភួងសាវ៉ាត បុប្ផា** | **ទូ យុង** |